ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២៤ អនក.បក

| នាយកដ្ឋានរដ្ឋបាលទូទៅ | |
|---|---|
| ទទួល | លេខៈ 3144 ទ.កបទ.សអ |
| | ថ្ងៃទី 17 ខែ 12 ឆ្នាំ 09 |
| | ម៉ោង 11h.00 |

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធីក្នុងការពិនិត្យទទួលស្គាល់ ផ្តល់ឋានៈជនភៀសខ្លួន ឬសិទ្ធិជ្រកកោន ដល់ជនបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៥ ន.ស.៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៥១ និងពិធីសារ ឆ្នាំ១៩៦៧ ដែលប្រទេសកម្ពុជាបានក្លាយទៅជាភាគីហត្ថលេខីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ស្តីពីឋានៈនៃជនភៀសខ្លួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីនីតិវិធីក្នុងការពិនិត្យទទួលស្គាល់ ផ្តល់ឋានៈជនភៀសខ្លួន ឬសិទ្ធិជ្រកកោនដល់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២.-

អនុក្រឹត្យនេះ មានគោលបំណងរួមចំណែកក្នុងការធានា ការគោរពសិទ្ធិមនុស្ស និងសិទ្ធិរបស់ជនភៀសខ្លួនក្នុងការអនុវត្តសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ខ្លួន ស្របតាមស្មារតីនៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៥១ និងពិធីសារឆ្នាំ ១៩៦៧ ស្តីពីឋានៈនៃជនភៀសខ្លួន។

មាត្រា៣.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសទាំងអស់ដែលមានបំណងសុំឋានៈជាជនភៀសខ្លួន ឬសិទ្ធិជ្រកកោននៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៤.-

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ ÷

**ជនភៀសខ្លួន** សំដៅដល់បុគ្គលដែលបំពេញបាននូវលក្ខខណ្ឌទាំងអស់ដូចខាងក្រោម:

-ស្ថិតនៅក្រៅប្រទេសដែលខ្លួនមានសញ្ជាតិ ឬបុគ្គលដែលមិនមានសញ្ជាតិ ហើយស្ថិតនៅក្រៅប្រទេសដែលខ្លួនធ្លាប់រស់នៅ

-មានការភ័យខ្លាចដោយមានហេតុផលជាក់លាក់ ពីការធ្វើទុក្ខបុកម្នេញដ៏ធ្ងន់ធ្ងរ ដោយសារមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមដោយឡែកណាមួយ ឬទស្សនៈនយោបាយ

-មិនអាច ឬមិនមានបំណងទទួលយកនូវការការពារពីប្រទេសនោះ ឬមិនអាច ឬមិនមានបំណងត្រឡប់ទៅកាន់ប្រទេសនោះវិញ ។

**ប្រទេសនៃសញ្ជាតិរបស់បុគ្គលដែលមានសញ្ជាតិលើសពីមួយ** សំដៅដល់រាល់ប្រទេសនីមួយៗដែលបុគ្គលនោះមានសញ្ជាតិ ហើយបុគ្គលម្នាក់មិនត្រូវចាត់ទុកថាខ្លួនឯងខ្វះនូវកិច្ចការពារពីប្រទេសនៃសញ្ជាតិរបស់ខ្លួនបានឡើយប្រសិនបើ :

-ពុំមានហេតុផលត្រឹមត្រូវណាមួយ ធ្វើជាមូលដ្ឋានស្តីពីការភ័យខ្លាច

-បុគ្គលនោះមិនព្រមទទួលយកនូវកិច្ចការពារពីប្រទេសណាមួយក្នុងចំណោមប្រទេសដែលខ្លួនមានសញ្ជាតិ ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

មាត្រា៥.-

ក្រសួងមហាផ្ទៃ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការពិនិត្យសម្រេច ឬមិនសម្រេចឱ្យជនបរទេសទទួលបានឋានៈជនភៀសខ្លួន ឬសិទ្ធិជ្រកកោននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាននាយកដ្ឋានអន្តោប្រវេសន៍នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ជាសេនាធិការ ។

ការទទួលស្គាល់ជនភៀសខ្លួន ការបញ្ឈប់ឋានៈជនភៀសខ្លួន និងការលុបចោលឋានៈជាជនភៀសខ្លួន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

# ជំពូកទី៣
## បែបបទក្នុងការផ្តល់សិទ្ធិជ្រកកោន

**មាត្រា៦.-**

ជនបរទេស អាចដាក់ពាក្យសុំសិទ្ធិជ្រកកោន ចំពោះមន្រ្តីមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា តាមរូបភាពណាមួយដែលសមស្រប ។ បុគ្គលនោះ ត្រូវបានកំណត់ថាជាអ្នកដាក់ពាក្យសុំ ។

អ្នកដាក់ពាក្យសុំអាចទទួលបានការអនុញ្ញាតឱ្យចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាជាបណ្តោះអាសន្នក្នុងឋានៈជាជនបរទេស មិនមែនអន្តោប្រវេសន្ត បើទោះបីអ្នកដាក់ពាក្យសុំបាន ឬមិនបានបំពេញតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៨ និងមាត្រា ១១ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ក៏ដោយ ។

**មាត្រា៧.-**

មន្រ្តីមានសមត្ថកិច្ចកម្ពុជាមានសិទ្ធិបដិសេធមិនឱ្យចូល ឬបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា ប្រសិនបើបុគ្គលនោះ÷

ក. នឹងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬ

ខ. បានប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងច្បាប់អន្តរជាតិ ដែលពាក់ព័ន្ធដទៃទៀត ឬ

គ. បានប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ មិនមានលក្ខណៈនយោបាយ នៅក្រៅព្រះរាជាណាចក្រកម្ពុជា មុនពេលទទួលឱ្យចូលប្រទេសនេះក្នុងឋានៈជាជនសុំសិទ្ធិជ្រកកោន ឬ

ឃ. មានជាប់ពិរុទ្ធពីបទប្រព្រឹត្តអំពើផ្ទុយពីគោលបំណង និងគោលការណ៍នានារបស់អង្គការសហប្រជាជាតិ ។

**មាត្រា៨.-**

ការអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំចូល និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែផ្តល់ឱ្យក្នុងលក្ខខណ្ឌដែលរយៈពេលនៃការស្នាក់នៅ ត្រូវក៏រិតមិនឱ្យហួសពីត្រឹមរយៈពេលសម្រាប់កិច្ចដំណើរការនីតិវិធីក្នុងការកំណត់ឋានៈជនភៀសខ្លួន ។

មន្រ្តីមានសមត្ថកិច្ច នៃក្រសួងមហាផ្ទៃ ត្រូវចេញការអនុញ្ញាតជាលាយលក្ខអក្សរសម្រាប់ការស្នាក់នៅជាបឋមដោយមិនគិតថ្លៃ ទាំងចំពោះបែបបទនៃការផ្តល់ទិដ្ឋាការចូលនៅលើលិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យសុំ ឬក៏ផ្តល់ជូនតាមរូបភាពជាលិខិតអនុញ្ញាតដោយមានពន្យល់ពីមូលហេតុដែលមានចុះហត្ថលេខា និងបោះត្រាត្រឹមត្រូវដោយអគ្គស្នងការនគរបាលជាតិកម្ពុជា ប្រសិនបើអ្នកដាក់ពាក្យសុំពុំមានលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរដែលមានតម្លៃស្មើផ្សេងទៀត ។

**មាត្រា៩.-**

សមាជិកគ្រួសារដែលកំពុងស្ថិតក្នុងបន្ទុករបស់អ្នកដាក់ពាក្យសុំសិទ្ធិជ្រកកោន ក៏ត្រូវទទួលបានសិទ្ធិស្មើគ្នា និងត្រូវមានកាតព្វកិច្ចដូចគ្នានឹងអ្នកដាក់ពាក្យសុំដែរ ។

## ជំពូកទី៤
## នីតិវិធីក្នុងការផ្តល់ឋានៈជនភៀសខ្លួន

**មាត្រា១០.-**

ការកំណត់ឋានៈជនភៀសខ្លួន ត្រូវធ្វើឡើងស្របទៅតាមនីតិវិធី ដូចខាងក្រោមនេះ÷

**ក. ជំហានទី១ :** បែបបទនៃពាក្យសុំឋានៈជនភៀសខ្លួន

-មន្ត្រីមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ ត្រូវផ្តល់ទម្រង់បែបបទពាក្យសុំឋានៈជនភៀសខ្លួន ដល់អ្នកដាក់ពាក្យសុំដើម្បីបំពេញ ចុះហត្ថលេខា ផ្តិតមេដៃ និងដាក់ពាក្យសុំជូនមន្ត្រីមានសមត្ថកិច្ចវិញក្នុងរយៈពេលយ៉ាងយូរបំផុត ០៧ (ប្រាំពីរ) ថ្ងៃ។

-អ្នកដាក់ពាក្យសុំត្រូវផ្តល់ព័ត៌មានជាលាយល័ក្ខអក្សរអំពីមូលហេតុជាក់លាក់ នៃការចាកចេញពីប្រទេសដើមរបស់ខ្លួន និងការសុំឋានៈជនភៀសខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួន ០១(មួយ) ច្បាប់ជូនមន្ត្រីមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់អ្នកដាក់ពាក្យសុំ ត្រូវទទួលបានជំនួយក្នុងការបំពេញទម្រង់បែបបទ។

**ខ. ជំហានទី២ :** ការធ្វើសម្ភាសន៍ ដើម្បីកំណត់ឋានៈជនភៀសខ្លួន

-ការធ្វើសម្ភាសន៍ដើម្បីកំណត់ឋានៈជនភៀសខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ ដោយមន្ត្រីមានសមត្ថកិច្ច០២ (ពីរ) រូបនៃក្រសួងមហាផ្ទៃ និង០១ (មួយ) រូបនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបន្ទាប់ពីទទួលបានពាក្យសុំ។ អ្នកដាក់ពាក្យសុំត្រូវបង្ហាញខ្លួន នៅក្នុងកិច្ចសម្ភាសន៍កំណត់ឋានៈជនភៀសខ្លួន និងមានសិទ្ធិពន្យល់អំពីហេតុផលផ្លូវច្បាប់ និងមនុស្សធម៌ ព្រមទាំងហេតុផលដទៃទៀត ដើម្បីទទួលបានឋានៈជនភៀសខ្លួន។

-នៅក្នុងកិច្ចសម្ភាសន៍ដើម្បីកំណត់ឋានៈជនភៀសខ្លួន មន្ត្រីមានសមត្ថកិច្ចត្រូវចងក្រងលំអិតទុកជាឯកសារអំពីអត្តសញ្ញាណអ្នកដាក់ពាក្យសុំ និងសមាជិកគ្រួសារដែលបានរួមដំណើរមកជាមួយគ្នា និង ត្រូវធ្វើយ៉ាងណាដើម្បីធានាថាអ្នកដាក់ពាក្យសុំបានផ្តល់នូវព័ត៌មានពាក់ព័ន្ធទាំងអស់ដែលមាន។ ចំពោះព័ត៌មានណាដែលមន្ត្រីមានសមត្ថកិច្ចយល់ឃើញថាមិនទាន់គ្រប់គ្រាន់ មន្ត្រីមានសមត្ថកិច្ចនោះត្រូវឱ្យអ្នកដាក់ពាក្យសុំផ្តល់ព័ត៌មានបន្ថែម។ មន្ត្រីមានសមត្ថកិច្ចត្រូវប្រមូល និងពិនិត្យព័ត៌មានចាំបាច់ដែលពាក់ព័ន្ធទាំងអស់ដើម្បីធ្វើការវាយតម្លៃទៅលើភាពត្រឹមត្រូវនៃការស្នើសុំ ។

- ក្នុងកិច្ចសម្ភាសន៍ខាងលើនេះ អ្នកដាក់ពាក្យសុំ ត្រូវបំភ្លឺឱ្យបានច្បាស់អំពីមូលហេតុ នៃការសុំឋានៈជនភៀសខ្លួន និងត្រូវជូនឯកសារ និងព័ត៌មានពាក់ព័ន្ធដទៃទៀតជាជំនួយបន្ថែមទៅលើពាក្យសុំ និងត្រូវសហការឱ្យបានពេញលេញនៅក្នុងកិច្ចដំណើរការនេះ។

កិច្ចសម្ភាសន៍ ដើម្បីផ្តល់ឋានៈជនភៀសខ្លួន ត្រូវធ្វើកំណត់ហេតុលំអិតរក្សាទុកជាឯកសារ។

**គ. ជំហានទី៣ :** នីតិវិធីនៃការធ្វើសេចក្តីសម្រេច

កិច្ចដំណើរការនីតិវិធីពិនិត្យផ្តល់ឋានៈជនភៀសខ្លួន ត្រូវធ្វើឡើងដោយមន្ត្រីមានសមត្ថកិច្ច ០២(ពីរ) រូប។ បន្ទាប់ពីការសរុបលទ្ធផលសម្ភាសន៍ជនភៀសខ្លួន សេចក្តីសម្រេចជាលាយល័ក្ខអក្សរមួយត្រូវធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលមិនលើសពី៤៥(សែសិបប្រាំ) ថ្ងៃ។ បើសិនជាសេចក្តីសម្រេចមិនអាចធ្វើបានក្នុង

រយៈពេលនេះដោយបណ្តាលមកពីប្រភេទរបស់ករណី មន្ត្រីមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ អាចពន្យារពេលក្នុងផេរវេលាមួយសមស្រប ប៉ុន្តែមិនត្រូវឱ្យលើសពី ៩០(កៅសិប) ថ្ងៃនៃរយៈពេលសរុបទេ ។ មន្ត្រីមានសមត្ថកិច្ចត្រូវធ្វើការ ជូនដំណឹងជាលាយលក្ខអក្សរបញ្ជាក់អំពីមូលហេតុជាក់លាក់ស្តីពីការពន្យារពេលនេះដល់អ្នកដាក់ពាក្យសុំ ។

បើសិនជាអ្នកដាក់ពាក្យសុំបានបំពេញនូវលក្ខខណ្ឌដូចមានចែងនៅក្នុងអនុក្រឹត្យនេះ បេក្ខជនត្រូវតែបាន ផ្តល់ឱ្យនូវឋានៈជនភៀសខ្លួន ។

បើសិនជាការសម្រេចអវិជ្ជមាន ត្រូវប្រាប់ហេតុផលដែលពាក្យសុំត្រូវបានបដិសេធ ។ អ្នកដាក់ពាក្យសុំអាចដាក់ពាក្យប្តឹងជំទាស់ទៅនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីឱ្យពិចារណាឡើងវិញអំពីសេចក្តីសម្រេចនោះ ក្នុងកំឡុងពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបាននូវការសរសេរជាអវិជ្ជមាននោះ។ អ្នកដាក់ពាក្យសុំត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការដាក់ពាក្យប្តឹងជំទាស់ ។ អ្នកដាក់ពាក្យប្តឹងជំទាស់ អាចធ្វើការប្តឹងជំទាស់បានតែម្តងគត់ ។

នាយកដ្ឋានអន្តោប្រវេសន៍ ត្រូវពិចារណាលើពាក្យប្តឹងជំទាស់ដើម្បីសម្រេចក្នុងកំឡុងពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យប្តឹងជំទាស់នោះ ។

នាយកដ្ឋានអន្តោប្រវេសន៍ ត្រូវបង្កើតក្រុមការងារថ្មីមួយដែលមានមន្ត្រីចំនួន ០៤ (បួន) រូប ដែលមិនធ្លាប់ចូលរួមក្នុងកិច្ចដំណើរការនៃនីតិវិធីពាក់ព័ន្ធនឹងការពិនិត្យផ្តល់ឋានៈជនភៀសខ្លួន លើកទីមួយដើម្បីពិចារណាលើបណ្តឹងជំទាស់នេះ ។

សេចក្តីសម្រេចណាមួយដែលត្រូវបានធ្វើឡើងក្រោយពីការពិចារណាលើបណ្តឹងជំទាស់នេះ ត្រូវចាត់ទុកជាសេចក្តីសម្រេចចុងក្រោយ ។ អ្នកដាក់ពាក្យសុំដែលត្រូវបានបដិសេធ ត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជាក្នុងអំឡុង ពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេចនោះ។

ការសម្រេចដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនេះ ត្រូវអនុវត្តភ្លាមទោះបីមានការជំទាស់ពីផ្នែកណាមួយនៃកិច្ចសហប្រតិបត្តិការក៏ដោយ ។

## មាត្រា១១.-

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ អាចបដិសេធចោលភ្លាមនូវពាក្យសុំឋានៈជនភៀសខ្លួន ដោយផ្អែកលើមូលហេតុណាមួយដូចខាងក្រោម ÷

ក.អ្នកដាក់ពាក្យសុំ មិនបានសហការជាមួយមន្ត្រីមានសមត្ថកិច្ចក្នុងការបញ្ជាក់ឱ្យបានត្រឹមត្រូវទាក់ទិនទៅនឹងពាក្យសុំរបស់ខ្លួន ឬ

ខ.អ្នកដាក់ពាក្យសុំបង្ហាញថា ការស្នើសុំនេះ គ្រាន់តែឈរលើមូលដ្ឋាននៃសេចក្តីត្រូវការខាងសេដ្ឋកិច្ច ឬក៏គ្រាន់តែមានបំណងកែលំអរជីវភាពរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ឬ

គ.អ្នកដាក់ពាក្យសុំ នៅក្នុងពេលកំពុងដំណើរការនីតិវិធីនេះបានប្រព្រឹត្តនូវអំពើណាមួយដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ។

## មាត្រា១២.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបញ្ឈប់កិច្ចដំណើរការនីតិវិធីផ្តល់ឋានៈជនភៀសខ្លួន ដោយមូលហេតុណាមួយដូចខាងក្រោម ÷

-អ្នកដាក់ពាក្យសុំ ស្លាប់នៅក្នុងពេលកំពុងដំណើរការនីតិវិធី ឬ

-អ្នកដាក់ពាក្យសុំ ដកពាក្យសុំរបស់ខ្លួនចេញដោយស្ម័គ្រចិត្ត ឬ

-អ្នកដាក់ពាក្យសុំ ខកខានមិនបានចូលរួមកិច្ចសម្ភាសន៍ចំនួន០២(ពីរ)លើកជាប់ៗគ្នា ដោយមិនមានមូលហេតុច្បាស់លាស់។

មាត្រា១៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្តល់អ្នកបកប្រែដោយឥតគិតថ្លៃដើម្បីជួយសម្រួលនៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចដំណើរការនីតិវិធីក្នុងការកំណត់ឋានៈជនភៀសខ្លួន ការបញ្ឈប់ ឬការលុបចោលឋានៈជនភៀសខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្តល់តំណាង ឬអ្នកអាណាព្យាបាលស្របច្បាប់ដល់អ្នកដាក់ពាក្យសុំដែលជាអនីតិជន ឬដែលមានពិការភាពដូចមានបញ្ញត្តិនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ តំណាង ឬអ្នកអាណាព្យាបាលនេះ ត្រូវធ្វើការក្នុងនាម និងដើម្បីផលប្រយោជន៍ដ៏ល្អបំផុតរបស់អ្នកដាក់ពាក្យសុំ។

មាត្រា១៤.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីវិធានការអនុវត្តកិច្ចដំណើរការនីតិវិធីផ្តល់ឋានៈជនភៀសខ្លួន និងអំពីការងារគ្រប់គ្រងបុគ្គលទាំងឡាយដែលបានដាក់ពាក្យសុំផ្តល់ឋានៈជនភៀសខ្លួន និងចំពោះបុគ្គលដែលត្រូវបានផ្តល់ឋានៈជនភៀសខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី៥
## សិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលដែលទទួលបានឋានៈជាជនភៀសខ្លួន

មាត្រា១៥.-

ជនភៀសខ្លួនគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន រួមទាំងវិធានការផ្សេងៗ ដែលទាក់ទងដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ។

ជនភៀសខ្លួនមានសិទ្ធិ និងកាតព្វកិច្ចដូចជនបរទេសអន្តោប្រវេសន៍ស្របច្បាប់ នៅពេលដែលជននោះត្រូវបានទទួលស្គាល់ឋានៈជាជនភៀសខ្លួន ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។

ប័ណ្ណស្នាក់នៅ និងការពន្យារសុពលភាពនៃប័ណ្ណស្នាក់នៅ ត្រូវបានផ្តល់ឱ្យដោយយោងតាមច្បាប់ស្តីពី អន្តោប្រវេសន៍ លើកលែងតែឋានៈជាជនភៀសខ្លួន ត្រូវបានបញ្ឈប់ ឬត្រូវបានលុបចោលដូចមានចែង នៅក្នុងជំពូកទី៦នៃអនុក្រឹត្យនេះ ។

មាត្រា១៦.-

ជនភៀសខ្លួនមានសិទ្ធិធ្វើការងារ ឬប្រកបមុខរបរអ្វីមួយបានស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា១៧.-

ជនភៀសខ្លួនមានសិទ្ធិធ្វើការធានាដល់ការធ្វើអន្តោប្រវេសន៍ នៃសមាជិកគ្រួសារក្នុងបន្ទុករបស់ខ្លួនមកកាន់ព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៨.-**

ជនភៀសខ្លួនត្រូវគោរពនូវកាតព្វកិច្ចទាំងអស់ និងទទួលបាននូវសិទ្ធិទាំងអស់ ដែលមានចែងនៅក្នុងអនុសញ្ញាឆ្នាំ ១៩៥១ និងពិធីសារឆ្នាំ ១៩៦៧ ស្តីពីឋានៈជនភៀសខ្លួន។

បើជនភៀសខ្លួន មានបំណងធ្វើដំណើរចេញពីព្រះរាជាណាចក្រកម្ពុជា ជនភៀសខ្លួនត្រូវមានសិទ្ធិទទួលបាននូវឯកសារធ្វើដំណើរ ដូចមានចែងនៅក្នុងមាត្រា ២៨ នៃអនុសញ្ញាឆ្នាំ១៩៥១ ទាក់ទិនទៅនឹងឋានៈជនភៀសខ្លួន ។

## ជំពូកទី៦
## ការមិនរាប់បញ្ចូល ការបញ្ឈប់ និងការលុបចោល ឋានៈជាជនភៀសខ្លួន

**មាត្រា១៩.-**

អ្នកដាក់ពាក្យសុំ មិនអាចត្រូវបានរាប់បញ្ចូល ឬផ្តល់ឋានៈជាជនភៀសខ្លួន បើសិនជាមានមូលហេតុណាមួយដូចខាងក្រោម ÷

-បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់អន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋទាំងនោះ ឬ

-បានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរមិនមានលក្ខណៈនយោបាយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មុននឹងមកដាក់ពាក្យសុំ ឬ

-មានជាប់ពិរុទ្ធពីបទប្រព្រឹត្តអំពើផ្ទុយនឹងគោលបំណង និងគោលការណ៍នានារបស់អង្គការសហប្រជាជាតិ។

**មាត្រា២០.-**

ឋានៈជនភៀសខ្លួន ដែលបានផ្តល់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនឹងត្រូវបញ្ឈប់ ប្រសិនបើមានមូលហេតុណាមួយដូចខាងក្រោម ÷

-ស្ម័គ្រចិត្តទទួលឡើងវិញនូវកិច្ចការពារពីប្រទេសដែលខ្លួនមានសញ្ជាតិ ឬ

-ទទួលបានឡើងវិញនូវសញ្ជាតិដែលខ្លួនបានបាត់បង់ ឬ

-ទទួលបាននូវសញ្ជាតិថ្មីមួយ និងសុខចិត្តទទួលយកកិច្ចការពារពីប្រទេសដែលខ្លួនទទួលបានសញ្ជាតិនោះ ឬ

-ស្ម័គ្រចិត្តទទួលបានឡើងវិញនូវការស្នាក់នៅ នៅក្នុងប្រទេសដែលខ្លួនបានគេចចេញ ដោយសារការភ័យខ្លាចអំពីការធ្វើទុក្ខបុកម្នេញ ឬ

-ដោយសារកាលៈទេសៈ ដែលជាហេតុផលនាំឱ្យខ្លួនត្រូវបានទទួលស្គាល់ជាជនភៀសខ្លួន លែងមានតទៅទៀត ហើយខ្លួនលែងបន្តបដិសេធនូវកិច្ចការពារពីប្រទេសដែលខ្លួនមានសញ្ជាតិតទៅទៀត ឬ

-ជាបុគ្គលដែលពុំមានសញ្ជាតិ ហើយមានលទ្ធភាពអាចត្រឡប់ទៅកាន់ប្រទេសដែលខ្លួនធ្លាប់រស់នៅជាធម្មតាពីអតីតកាលពីព្រោះថាកាលៈទេសៈដែលជាមូលហេតុនាំឱ្យខ្លួន ត្រូវបានទទួលស្គាល់ជាជនភៀសខ្លួន នោះលែងមានតទៅទៀតហើយ។

មាត្រា២១.-

ឋានៈជនភៀសខ្លួន ដែលបានផ្តល់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនឹងត្រូវលុបចោលដោយហេតុផលណាមួយដូចខាងក្រោម ÷

-នៅពេលដែលមាន ភស្តុតាងជាក់លាក់បង្ហាញថា ឋានៈជនភៀសខ្លួន ត្រូវបានផ្តល់ដោយផ្អែកលើមូលដ្ឋានព័ត៌មាន ឯកសារ ឬសម្ភារៈមិនពិត ឬក្លែងក្លាយ ដែលផ្តល់ដោយចេតនាដោយជនភៀសខ្លួន ឬ

-ពេលដែលមានការបញ្ជាក់ដោយមានហេតុផលត្រឹមត្រូវថា អ្នកដាក់ពាក្យសុំបានលាក់បាំងដោយចេតនានូវព័ត៌មាន សំខាន់ក្នុងដំណើរការកំណត់ឋានៈជនភៀសខ្លួន ឬ

-ជនភៀសខ្លួនស្នើសុំជាលាយលក្ខអក្សរ ដើម្បីលុបចោលឋានៈជនភៀសខ្លួនដោយគ្មានការបង្ខិតបង្ខំ ។

## ជំពូកទី៧
## ការបណ្តេញចេញ

មាត្រា២២.-

គ្មានជនភៀសខ្លួនណាមួយត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែជនភៀសខ្លួនដែលមានអាកប្បកិរិយា និងសកម្មភាពនាំឱ្យមានគ្រោះថ្នាក់ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ។

ការបណ្តេញចេញជនភៀសខ្លួនត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ។ ការបណ្តេញចេញក្នុងលក្ខខណ្ឌនេះ ជនភៀសខ្លួន មានសិទ្ធិបង្ហាញភស្តុតាងដើម្បីតវ៉ា ព្រមទាំងអាចស្នើសុំឱ្យមានតំណាងរបស់ខ្លួនការពារនៅចំពោះអាជ្ញាធរមានសមត្ថកិច្ច ។

ស្ថាប័នមានសមត្ថកិច្ចត្រូវផ្តល់ពេលវេលាសមស្របអោយជនភៀសខ្លួនដែលត្រូវបណ្តេញចេញ អាចស្វែងរកសុំការអនុញ្ញាតឱ្យចូលទៅរស់នៅក្នុងទឹកដីនៃប្រទេសមួយផ្សេងទៀត ។ មន្ត្រីមានសមត្ថកិច្ចមានសិទ្ធិក្នុងការអនុវត្តតាមវិធានការផ្ទៃក្នុងទាំងឡាយ ដែលយល់ថាជាការចាំបាច់នៅក្នុងកំឡុងពេលរង់ចាំ ។

មាត្រា២៣.-

ជនភៀសខ្លួនមិនត្រូវបានបណ្តេញ ឬបញ្ជូនត្រឡប់ទៅវិញ តាមវិធីណាក៏ដោយទៅកាន់ព្រំដែននៃទឹកដីដែលជីវិត សេរីភាព និងសិទ្ធិមនុស្សរបស់គេនឹងត្រូវគំរាមកំហែងដោយសារបញ្ហាពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមដោយឡែកណាមួយ ឬទស្សនៈនយោបាយ ។

## ជំពូកទី៨
## កិច្ចសហប្រតិបត្តិការជាមួយ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

**មាត្រា២៤.-**

ក្រសួងមហាផ្ទៃ ត្រូវផ្តល់ជូនឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជានូវច្បាប់ចម្លងនៃពាក្យសុំ សេចក្តីសម្រេច និងឯកសារពាក់ព័ន្ធដទៃទៀត។ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ក៏អាចជួយសម្របសម្រួល ឬផ្តល់ជាអនុសាសន៍ក្នុងកិច្ចដំណើរការទាំងអស់ដែលត្រូវបានធ្វើឡើងអនុលោមតាមអនុក្រឹត្យនេះ។

ក្រសួងមហាផ្ទៃ ត្រូវធ្វើកិច្ចសហប្រតិបត្តិការអោយបានល្អជាមួយ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅក្នុងការអនុវត្តបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ និងអនុសញ្ញាឆ្នាំ១៩៥១ និងពិធីសារឆ្នាំ១៩៦៧ ស្តីពីឋានៈជនភៀសខ្លួន។

អ្នកសុំឋានៈជនភៀសខ្លួន ឬសិទ្ធិជ្រកកោន អាចទាក់ទងជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងមហាផ្ទៃបានគ្រប់ពេលវេលា។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៥ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

បានយកសេចក្តីគោរពជូន
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាសូមចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង